# កុំភ្លេចខ្ញុំ

*ដោយប្រធាន ឌៀថើរ អេស្វ អុជដូហ្វ*
*ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ*

បងប្អូនស្រីជាទីស្រឡាញ់របស់ខ្ញុំ នៅថ្ងៃនេះខ្ញុំមានរីករាយណាស់ដែលបាននៅជាមួយអ្នករាល់គ្នា ។ ខ្ញុំតែងតែទន្ទឹងរង់ចាំការប្រជុំសមាគមសង្គ្រោះទូទៅប្រចាំឆ្នាំនេះ និងសារលិខិតដែលបានធ្វើឡើងនៅទីនេះ ។ ខ្ញុំមានកិត្តិយសខ្លាំងណាស់ ដើម្បីបន្ថែមគំនិតមួយចំនួនប្រាប់ទៅកាន់បងប្អូនស្រីនៃសាសនាចក្រនេះ ។

ជាយូរហើយ កាលខ្ញុំកំពុងដើរក្នុងសួនដ៏ស្រស់ស្អាតមួយជាមួយនឹងភរិយា ព្រមទាំងកូនស្រីខ្ញុំ ។ ខ្ញុំមានចិត្តស្ញប់ស្ញែងដល់ភាពរុងរឿង និងភាពស្រស់ស្អាតនៃការបង្កបង្កើតរបស់ព្រះ ។ រួចហើយខ្ញុំបានសម្គាល់ឃើញថាមានផ្កាដ៏តូចមួយ នៅក្នុងចំណោមផ្កាដែលរីកស្គុះស្គាយជាច្រើន។ ខ្ញុំស្គាល់ឈ្មោះផ្កានេះ ដោយសារពីក្មេងខ្ញុំមាននិស្ស័យនឹងវា ។ ផ្កានេះឈ្មោះថា កុំភ្លេចខ្ញុំ ។

ខ្ញុំមិនបានចាំច្បាស់ថាហេតុអ្វីផ្កាមួយនេះមានន័យចំពោះខ្ញុំខ្លាំងជាច្រើនឆ្នាំមកដូច្នេះទេ ។ វាពុំសូវទាក់ភ្នែកទេ វាងាយនឹងមើលរំលងក្នុងចំណោមផ្កាធំៗ និងមានពណ៌ចំរុះដ៏ច្រើន ប៉ុន្តែវាស្រស់ស្អាតណាស់ ដោយសារពណ៌ដ៏ឆើតឆាយរបស់វាខៀវដូចជាផ្ទៃមេឃ ។ នោះប្រហែលជាមូលហេតុមួយទៀតដែលខ្ញុំចូលចិត្តវាខ្លាំង ។

ហើយឈ្មោះវាមានការទាក់ទាញណាស់ ។ មានរឿងព្រេងអាល្លឺម៉ង់មួយបានដំណាលថា កាលព្រះបានដាក់ឈ្មោះរុក្ខជាតិទាំងអស់ហើយ នោះក៏ភ្លេចដាក់ឈ្មោះឲ្យផ្កាមួយ ។ ក៏មានសម្លេងដ៏តូចមួយបានបន្លឺឡើងថា « ឱ! ព្រះអម្ចាស់អើយ សូមកុំភ្លេចទូលបង្គំ! » រួចព្រះមានបន្ទូលតបថា នេះហើយជាឈ្មោះឯង ។

រាត្រីនេះ ខ្ញុំចង់ប្រើផ្កាតូចនេះធ្វើជារឿងប្រៀបធៀបមួយ ។ ត្របកទាំងប្រាំនៃផ្កាកុំភ្លេចខ្ញុំ បំផុសខ្ញុំឲ្យពិចារណាពីរឿងប្រាំយ៉ាងដែលយើងមិនត្រូវភ្លេចឡើយ។

**ទីមួយ កុំភ្លេចអត់ធ្មត់នឹងខ្លួនឯង**

ខ្ញុំចង់ប្រាប់អ្នកពីរឿងមួយដែលខ្ញុំសង្ឃឹមថា អ្នកនឹងយល់បានត្រឹមត្រូវគឺ ៖ ព្រះពិតជាជ្រាបដឹងថា អ្នកនឹងខ្ញុំគឺជាមនុស្សមិនឥតខ្ចោះ ។ ខ្ញុំសូមបន្ថែមថា ៖ ព្រះក៏ជ្រាបដឹងទាំងស្រុងថាមនុស្សដែលអ្នកគិតថាឥតខ្ចោះគឺវាមិនដូច្នោះឡើយ ។

មែនហើយ យើងបានចំណាយពេល និងកម្លាំងជាច្រើនដើម្បីប្រៀបធៀបខ្លួនឯងនឹងអ្នកដទៃ --- ជាធម្មតាប្រៀបធៀបចំណុចទន់ខ្សោយខ្លួននឹងចំណុចខ្លាំងអ្នកដទៃ ។ ការណ៍នេះនាំឲ្យយើងបង្កើតនូវការរំពឹងទុកមួយពីខ្លួនឯងដែលយើងមិនអាចធ្វើបាន ។ ជាលទ្ធផល យើងមិនដែលត្រេកអរនឹងការខិតខំល្អៗរបស់យើងឡើយ ពីព្រោះវាហាក់ដូចជាពុំសូវបានល្អដូចជាអ្នកផ្សេងទៀតធ្វើ ។

មនុស្សគ្រប់គ្នាមានភាពខ្លាំង និងខ្សោយ ។ វាជាការល្អដែលអ្នកមានភាពខ្លាំង ។ វាជាផ្នែកមួយនៃបទពិសោធន៍ក្នុងជីវិតរមែងស្លាប់អ្នក ដែលអ្នកមានភាពទន់ខ្សោយ ។

ព្រះចង់ឲ្យយើងបង្វែរភាពទន់ខ្សោយយើងទៅជាភាពខ្លាំង[1] ប៉ុន្តែទ្រង់ជ្រាបដឹងថានេះជាគោលដៅមួយដ៏យូរអង្វែង ។ ទ្រង់ចង់ឲ្យយើងបានប្រែក្លាយជាល្អឥតខ្ចោះដូចទ្រង់[2] ហើយបើយើងបន្តនៅលើផ្លូវនៃភាពជាសិស្សនេះ ថ្ងៃណាមួយយើងនឹងក្លាយដូចទ្រង់ ។ វាមិនថ្វីទេ បើអ្នកពុំទាន់ទៅដល់ចំណុចនោះនៅឡើយ ។ សូមបន្តជឿនទៅមុខ ហើយឈប់ដាក់ទោសដល់ខ្លួនឯងទៀត ។ បងប្អូនស្រីជាទីស្រឡាញ់ ភាគច្រើនអ្នករាល់គ្នាមានក្ដីអាណិត និងចិត្តអត់ធ្មត់ជាបន្តបន្ទាប់ចំពោះភាពទន់ខ្សោយរបស់អ្នកដទៃ។ ក៏សូមចងចាំផងដែរត្រូវមានក្ដីអាណិត និងចិត្តអត់ធ្មត់ចំពោះខ្លួនឯងដែរ ។

នៅពេលនេះ សូមមានអំណរគុណចំពោះជោគជ័យតូចៗដែលកើតមាននៅក្នុងផ្ទះអ្នក ក្នុងទំនាក់ទំនងនឹងគ្រួសារអ្នក ក្នុងការអប់រំ និងក្នុងការចិញ្ចឹមជីវិតអ្នក ក្នុងការចូលរួមនៅសាសនាចក្រ និងការអភិវឌ្ឍន៍ខ្លួនអ្នក ។ ដូចជាផ្កាកុំភ្លេចខ្ញុំផងដែរ ជោគជ័យទាំងនេះហាក់ដូចជាតូចតាចចំពោះអ្នក ហើយ

ប្រហែលជាត្រូវអ្នកដទៃមើលរំលង ប៉ុន្តែព្រះទតឃើញការណ៍ទាំងនោះ ហើយវាធំណាស់ចំពោះទ្រង់ ។ បើអ្នករាប់ថាជោគជ័យជាការផ្កាកុលាប ឬផ្កាកេសរដ៏ស្រស់ស្អាតតែម្យ៉ាងនោះ នោះអ្នកអាចនឹងមើលរម្លងនូវបទពិសោធន៍ដ៏ផ្អែមល្ហែមនៃជីវិត ។

ឧទាហរណ៍ថាអ្នកចង់បាន « *រូបភាពដ៏ឥតខ្ចោះ* » មួយនៃរាត្រីជួបជុំក្រុមគ្រួសាររៀងរាល់សប្តាហ៍ --- ទោះបីជាការធ្វើដូច្នោះធ្វើឲ្យអ្នក និងមនុស្សជុំវិញខ្លួនមិនសប្បាយចិត្តក្តី --- នោះមិនមែនជាជម្រើសដ៏ប្រសើរបំផុតឡើយ ។ ផ្ទុយទៅវិញ សូមសួរខ្លួនឯងថា « តើយើងគួរធ្វើអ្វីជាគ្រួសារ ដើម្បីឲ្យមានភាពរីករាយ និងមានជីវភាពខាងវិញ្ញាណ ហើយធ្វើឲ្យបានស្និទ្ធស្នាលនឹងគ្នា ? » រាត្រីជួបជុំក្រុមគ្រួសារនោះ --- ទោះជាវាមិនសូវមានភាពធំដុំក្នុងបំណង និងការអនុវត្តន៍ក្តី --- ក៏វាអាចមានលទ្ធផលវិជ្ជមានដ៏យូរអង្វែងដែរ ។

ការធ្វើដំណើរយើងទៅកាន់ភាពល្អឥតខ្ចោះគឺយូរអង្វែង ប៉ុន្តែយើងអាចរកឃើញនូវភាពល្អអស្ចារ្យ និងរីករាយ សូម្បីតែនៅក្នុងជំហានដ៏តូចបំផុតនៃការធ្វើដំណើរនោះក្តី ។

**ទីពីរ កុំភ្លេចនូវភាពខុសគ្នារវាងការពលិកម្មល្អ និងការពលិកម្មឆោតល្ងង់**

ការពលិកម្មដែលអាចទទួលយកបានគឺពេលយើងលះបង់អ្វីមួយល្អសម្រាប់អ្វីមួយទៀតដែលមានតម្លៃមហិមាជាងនោះ ។ ការលះបង់ការសម្រាកបន្តិចបន្តួចសម្រាប់ក្មេងម្នាក់ដែលមានសុបិនអាក្រក់គឺជាការពលិកម្មល្អ ។ ការមិនបានដេកពេញមួយយប់ ដោយនាំឲ្យខូចសុខភាពយើងដើម្បីធ្វើនូវគ្រឿងបន្ទាប់បន្សំដ៏ល្អឥតខ្ចោះសម្រាប់សំលៀកបំពាក់ថ្ងៃអាទិត្យរបស់កូនស្រីម្នាក់ប្រហែលពុំមែនជាការពលិកម្មដ៏ល្អមួយឡើយ ។

ការចំណាយពេលយើងមួយចំនួនសម្រាប់ការសិក្សាព្រះគម្ពីរ ឬការរៀបចំមេរៀនដើម្បីបង្រៀនជាការពលិកម្មល្អមួយ ។ ការចំណាយពេលជាច្រើនម៉ោងរៀនដេរដាក់ចំណងជើងមេរៀនលើប្រដាប់កាន់ឆ្នាំង សម្រាប់សមាជិកថ្នាក់អ្នកម្នាក់ៗ នោះមិនមែនជាការចំណាយពេលល្អឡើយ ។

មនុស្សគ្រប់រូប និងគ្រប់ស្ថានភាពគឺខុសគ្នា ហើយការពលិកម្មល្អនៅក្នុងឧទាហរណ៍មួយអាចជាការពលិកម្មដ៏ឆោតល្ងង់ចំពោះឧទាហរណ៍មួយទៀត ។ តើយើងអាចប្រាប់ពីភាពខុសគ្នាសម្រាប់ស្ថានភាពយើងផ្ទាល់ដោយរបៀបណា? យើងអាចសួរខ្លួនឯងថា « តើខ្ញុំកំពុងចំណាយពេល និងកម្លាំងខ្ញុំចំពោះអ្វីដែលមានសារៈសំខាន់បំផុតដែរឬទេ ? » មានរឿងល្អៗជាច្រើនដើម្បីធ្វើ តែយើងមិនអាចធ្វើវាទាំងអស់បានឡើយ ។ ព្រះវរបិតាសួគ៌យើងមានព្រះទ័យរីករាយបំផុត ពេលយើងលះបង់អ្វីមួយល្អសម្រាប់អ្វីមួយដែលល្អជាងនោះក្នុងទស្សនៈដ៏អស់កល្ប ។ ពេលខ្លះ កិច្ចការនោះអាចមានន័យថាការថែទាំផ្កាកុំភ្លេចខ្ញុំដ៏តូច ហើយស្រស់ស្អាតមួយ ជំនួសឲ្យការមើលថែសួនដ៏ធំដែលមានផ្កាប្លែកៗជាច្រើន ។

**ទីបី កុំភ្លេចសប្បាយរីករាយនៅក្នុងពេលឥឡូវនេះ**

ក្នុងរឿងនិទានកុមារមួយ ដែលមានចំណងជើងថា *ឆាលី និងនិងរោងចក្រស្ករសូកូឡា* គឺមានអ្នកធ្វើស្ករដ៏ចម្លែកម្នាក់ឈ្មោះវិល្លី វ៉ុងកា លាក់សំបុត្រពណ៌មាសមួយក្នុងស្ករចំនួនប្រាំគ្រាប់ ហើយបានប្រកាសថា បើអ្នកណារកឃើញសំបុត្រមួយនឹងបានដើរទស្សនារោងចក្រគាត់ និងទទួលបានស្ករសូកូឡាពេញមួយជីវិត ។

នៅលើសំបុត្រពណ៌មាសនីមួយៗមាននូវសារនេះ ៖ « សូមចូលរួមអបអរដល់អ្នកដែលរកឃើញសំបុត្រពណ៌មាសនេះ ! ... មានអ្វីអស្ចារ្យជាច្រើនបានទុកសម្រាប់អ្នក ! មានរឿងដែលគួរឲ្យភ្ញាក់ផ្អើលជាច្រើនកំពុងរង់ចាំអ្នក ... ជាការភ្ញាក់ផ្អើលដ៏អាថ៌កំបាំង ហើយនិងអស្ចារ្យ ...នឹងធ្វើឲ្យអ្នករីករាយ ... ភ្ញាក់ផ្អើល និងភាន់ច្រឡំដល់អ្នក » ។ [3]

ក្នុងរឿងបុរាណរបស់កុមារនេះ មនុស្សទូទាំងពិភពលោកចង់បានសំបុត្រពណ៌មាសនោះយ៉ាងខ្លាំង ។ មនុស្សខ្លះគិតថាសុភមង្គលនាពេលអនាគតរបស់ខ្លួន ផ្អែកទៅលើថាតើសំបុត្រពណ៌មាសនឹងធ្លាក់មកលើដៃពួកគេឬអត់។ ដោយចិត្តអន្ទះសាររបស់ខ្លួន មានមនុស្សជាច្រើនបានចាប់ផ្តើមភ្លេចពីក្តីអំណរដ៏សាមញ្ញ ដែលពួកគេបានមានក្នុងការស្វែងរកស្ករគ្រាប់នោះ ។ ស្ករគ្រាប់នោះនឹងគ្មានតម្លៃឡើយបើគ្មានសំបុត្រពណ៌មាសនោះ ។

សព្វថ្ងៃនេះ មានមនុស្សជាច្រើនកំពុងរង់ចាំសំបុត្រមាសរបស់ខ្លួន --- ជាសំបុត្រដែលពួកគេជឿថា ជាគន្លឹះនាំទៅរកសុភមង្គលដែលពួកគេតែងស្រមៃចង់បាន ។ សម្រាប់មនុស្សខ្លះ សំបុត្រមាសនោះ អាចជាអាពាហ៍ពិពាហ៍ដ៏ល្អឥតខ្ចោះមួយ សម្រាប់មនុស្សខ្លះទៀត វាជាផ្ទះដ៏ស្រស់ស្អាត ឬប្រហែលជាការគ្មានកង្វល់ ឬគ្មានការព្រួយបារម្ភ ។

គ្មានអ្វីខុសឆ្គងក្នុងការប្រាថ្នាចង់បាននូវអ្វីដែលសុចរិតឡើយ --- យើងសង្ឃឹម ហើយស្វែងរកអ្វីដែលមាន « គុណធម៌ គួរស្រឡាញ់ ឬឈ្មោះល្អ ឬក៏គួរឲ្យសរសើរ » ។ [4] បញ្ហាកើតឡើងនៅពេលយើងទុកសុភមង្គលយើងចោលមួយអន្លើរ កាលដែលរង់ចាំហេតុការណ៍នាអនាគត --- ជាសំបុត្រមាសយើង --- កើតឡើង ។

មានស្ត្រីម្នាក់ប្រាថ្នាចង់រៀបការនឹងអ្នកកាន់បព្វជិតភាពដ៏សុចរិតម្នាក់នៅក្នុងព្រះវិហារបរិសុទ្ធ ហើយធ្វើជាម្ដាយ និងជាភរិយាម្នាក់លើសអ្វីៗទាំងអស់ ។ គាត់បានស្រមៃពីថ្ងៃនេះពេញមួយជីវិត តើគាត់នឹងក្លាយជាម្ដាយដ៏ឆ្នើម និងជាភរិយាដ៏គួរឲ្យស្រឡាញ់យ៉ាងណាទៅ។ គេហដ្ឋានគាត់នឹងពោរពេញទៅដោយក្ដីស្រឡាញ់ និងក្ដីសន្ដោ ។ គ្មានការប្រើពាក្យសម្ដីដែលជូរចត់ ។ អាហារមិនដែលខ្លោច ។ ហើយកូនៗគាត់វិញ ជំនួសឲ្យទៅដើរលេងនឹងមិត្តភក្ដិនឹងមានចំណង់ចិត្តដើម្បីចំណាយពេលល្ងាច និងចុងសប្ដាហ៍ជាមួយនឹងឪពុកម្ដាយវិញ ។

នេះជាសំបុត្រមាសរបស់គាត់ ។ វាជារឿងមួយដែលគាត់មានអារម្មណ៍ថា ជីវិតគាត់ទាំងមូលត្រូវការ ។ វាជារឿងមួយនៅក្នុងពិភពលោកទាំងមូលដែលគាត់ប្រាថ្នាចង់បានបំផុត ។

តែវាពុំដែលកើតឡើងឡើយ ។ ហើយកាលពេលវេលាចេះតែកន្លងទៅ គាត់ចាប់ផ្ដើមដកខ្លួនថយ ហើយមានភាពជូរចត់ ថែមទាំងមាននូវកំហឹងផងដែរ ។ គាត់មិនយល់សោះ ថាហេតុអ្វីបានជាព្រះមិនប្រទានពរឲ្យស្របតាមក្ដីប្រាថ្នាដ៏សុចរិតនេះដូច្នេះ ។

គាត់ធ្វើជាគ្រូបង្រៀននៅថ្នាក់បឋមសិក្សា ហើយការនៅក្បែរក្មេងៗពេញមួយថ្ងៃ ជាការរំលឹកដល់គាត់ថា សំបុត្រមាសរបស់គាត់នឹងពុំកើតឡើងឡើយ ។ កាលពេលវេលាចេះតែកន្លងទៅ គាត់កាន់តែខកបំណង ហើយដកខ្លួនថយ ។ មានមនុស្សជាច្រើនមិនចូលចិត្តនៅជិតគាត់ ហើយគេចពីគាត់តាមដែលគេអាចធ្វើបាន ។ គាត់ថែមទាំងបញ្ចេញកំហឹងទៅលើក្មេងៗនៅឯសាលារៀនទៀតផង ។ គាត់ដឹងខ្លួនថា គាត់ចាប់ផ្ដើមបាត់ការអត់ធ្មត់ ហើយមានកំហឹង និងភាពឯកោយ៉ាងខ្លាំង ។

ភាពសោកសៅនៃរឿងនេះគឺថាស្ត្រីរូបនេះបានបរាជ័យក្នុងការមើលឃើញពីពរជ័យដែលខ្លួន*មាន* ដោយសារតែការខកចិត្តចំពោះសំបុត្រមានរបស់គាត់ ។ គាត់គ្មានកូននៅក្នុងផ្ទះមែន តែគាត់មានក្មេងរុំពេញនៅក្នុងថ្នាក់ ។ គាត់មិនបានប្រទានពរឲ្យមានគ្រួសារមែន តែព្រះអម្ចាស់បានប្រទានពរដល់គាត់ឲ្យមានឱកាសមួយ ដែលមានតែមនុស្សមួយចំនួនអាចមានប៉ុណ្ណោះ--- ជាឱកាសដើម្បីផ្ដល់ជាឥទ្ធិពលល្អដល់ជីវិតកុមាររាប់រយនាក់ និងក្រុមគ្រួសារក្នុងនាមជាគ្រូបង្រៀន ។

មេរៀននៅត្រង់នេះគឺថា បើយើងចំណាយពេលយើងរង់ចាំផ្កាកុលាបដ៏ស្រស់ នោះយើងអាចនឹងមើលរំលងនូវសម្រស់ និងភាពអស្ចារ្យនៃផ្កាកុំភ្លេចខ្ញុំដែលមាននៅជុំវិញខ្លួនយើង ។

នេះពុំមានន័យថា យើងគួរតែបោះបង់ចោលក្ដីសង្ឃឹម ឬគោលដៅយើងនោះទេ ។ សូមកុំឈប់ព្យាយាមរកអ្វីដែលល្អបំផុតក្នុងខ្លួនអ្នក ។ សូមកុំលះបង់ក្ដីសង្ឃឹមសម្រាប់ក្ដីប្រាថ្នាសុចរិតទាំងអស់ដែលមាននៅក្នុងចិត្តអ្នក ។ ប៉ុន្តែសូមកុំបិទភ្នែក និងបិទដួងចិត្តអ្នក ចំពោះភាពស្រស់ស្អាតយ៉ាងសាមញ្ញនៃពេលធម្មតាជារៀងរាល់ថ្ងៃ ដែលវាធ្វើឲ្យមានជីវិតស្រស់បំព្រងនោះឡើយ ។

មនុស្សដ៏មានសុភមង្គលបំផុតដែលខ្ញុំបានស្គាល់គឺពុំមែនជាអ្នកដែលស្វែងរកសំបុត្រមាសខ្លួននោះទេ តែពួកគេជាអ្នកដែល រកឃើញ ហើយរក្សានូវស្រស់ស្អាត និងភាពផ្អែមល្ហែមដែលកើតមានគ្រប់ពេលជារៀងរាល់ថ្ងៃ ខណៈដែលព្យាយាមសម្រេចនូវគោលដៅដ៏សក្តិសម ។ ពួកគេជាអ្នកដែលបោះជំហានទៅមុខសន្សឹមៗ បង្កើតឲ្យមានអារម្មណ៍នៃអំណរគុណ និងស្ងប់ស្ងែងចំពោះជីវិតខ្លួន ។ ទាំងនេះហើយជាអ្នកដែលមានក្ដីរីករាយពិត ។

**ទីបួន កុំភ្លេចពី « ហេតុផល » នៃដំណឹងល្អ ។**

ពេលខ្លះ ជាទម្លាប់នៃជីវិតយើង យើងបានមើលរម្លងដោយអចេតនានូវទិដ្ឋភាពដ៏សំខាន់នៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដូចជាមនុស្សម្នាក់ដែលអាចមើលរម្លងនូវភាពស្រស់ស្អាតនៃផ្កាកុំភ្លេចខ្ញុំដែរ ។ នៅក្នុងការខស្វាហ៍ព្យាយាមរបស់យើងដើម្បីបំពេញករណីយកិច្ច និងកាតព្វកិច្ចដែលយើងមានក្នុងនាមជាសមាជិកនៃសាសនាចក្រនេះ នៅពេលខ្លះ យើងគិតថាដំណឹងល្អដូចជាបញ្ជីការងារមួយដ៏វែង ដែលយើងត្រូវតែដាក់បន្ថែមនៅក្នុងបញ្ជី « កិច្ចការដែលត្រូវធ្វើ » ដ៏ច្រើនដែលយើងមានរួចហើយ ជាចន្លោះពេលមួយយើងត្រូវតែធ្វើឲ្យបានជាមួយនឹងកាលវិភាគដ៏រវល់របស់យើង មិន

ថាដោយរបៀបណានោះទេ ។ យើងយកចិត្តទុកដាក់ទៅលើ *អ្វី* ដែលព្រះអម្ចាស់ចង់ឲ្យយើងធ្វើ និង*របៀប* ដែលយើងអាចធ្វើវាបាន តែពេលខ្លះយើងភ្លេចពី *ហេតុអ្វី* ។

បងប្អូនស្រីជាទីស្រឡាញ់របស់ខ្ញុំ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ មិនមែនជាកាតព្វកិច្ចនោះទេ វាជាផ្លូវដែលបានគូសដោយព្រះវរបិតាជាទីស្រឡាញ់របស់យើង ដោយដឹកនាំទៅរកសុភមង្គល និងសេចក្ដីសុខសាន្តក្នុងជីវិតនេះ និងសិរីល្អ ព្រមទាំងជោគជ័យដែលមិនអាចពិពណ៌នាបាននៅជីវិតខាងមុខ ។ ដំណឹងល្អជាពន្លឺដែលចាក់ទម្លុះចូលទៅក្នុងជីវិតរមែងស្លាប់ ហើយនិងបំភ្លឺផ្លូវដែលនៅពីមុខយើង ។

ខណៈដែលយល់ដឹងពីដំណឹងល្អ និងរបៀបដែលវាដំណើរការគឺចាំបាច់ នោះភ្លើងដ៏អស់កល្ប និងអំណាចនៃដំណឹងល្អនាពេលខាងមុខមកពី « មូលហេតុ » ។ នៅពេលយើងយល់ពី *ហេតុផល* ដែលព្រះវរបិតាសួគ៌យើងបានប្រទានដល់យើងនូវគំរូនៃការរស់នៅ នៅពេលយើងចងចាំពី*មូលហេតុ* ដែលយើងបានប្ដេជ្ញាចិត្តដើម្បីធ្វើឲ្យវាក្លាយជាផ្នែកមួយដ៏សំខាន់ក្នុងជីវិតយើង នោះដំណឹងល្អនឹងឈប់ធ្វើជាបន្ទុកទៀតហើយ តែផ្ទុយទៅវិញ ដំណឹងល្អនឹងក្លាយទៅជាក្ដីអំណរ និងក្ដីរីករាយ។ វានឹងក្លាយទៅជារឿងដ៏មានតម្លៃ និងផ្អែមល្ហែម ។

សូមយើងកុំដើរនៅលើផ្លូវនៃភាពជាសិស្សដោយភ្នែករបស់យើងសម្លឹងមើលទៅដី ដោយគិតតែពីការងារ និងកាតព្វកិច្ចដែលមាននៅចំពោះមុខយើងឡើយ ។ ចូរយើងកុំដើរនៅលើផ្លូវដែលមិនស្គាល់ពីភាពស្រស់ស្អាតនៃសិរីរុងរឿងលើលោកិយ និងទេសភាពខាងវិញ្ញាណដែលមាននៅជុំវិញយើងឡើយ ។

បងប្អូនស្ត្រីជាទីស្រឡាញ់ សូមឲ្យអ្នកស្វែងរកអានុភាព សម្រស់ និងក្ដីរីរាយដ៏ក្រៃលេងមកពី « ហេតុផល » នៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

ការគោរពប្រតិបត្តិគូសផ្លូវឲ្យយើង និងរក្សាយើងនៅលើផ្លូវត្រឹមត្រូវ ។ « ហេតុផល » នៃការប្រតិបត្តិធ្វើឲ្យសកម្មភាពយើងបានបរិសុទ្ធ ដោយធ្វើឲ្យរឿងធម្មតាប្រែក្លាយទៅជារឿងដែលមានឥទ្ធិពល ។ វាបង្កើនទង្វើតូចៗនៃការប្រតិបត្តិរបស់យើង ទៅជាទង្វើដ៏បរិសុទ្ធនៃការឧទ្ទិស ។

**ទីប្រាំ កុំភ្លេចថាព្រះអម្ចាស់ស្រឡាញ់អ្នក ។**

កាលពីក្មេងពេលខ្ញុំសម្លឹងមើលផ្កាកុំភ្លេចខ្ញុំ ពេលខ្លះខ្ញុំមានអារម្មណ៍ថាខ្លួនឯងតូចដូចជាផ្កានោះដែរ --- គឺតូច ហើយមិនសូវសំខាន់ ។ ខ្ញុំងឿងឆ្ងល់ថាតើខ្ញុំនឹងត្រូវបានគ្រួសារខ្ញុំ ឬព្រះវរបិតាសួគ៌ខ្ញុំបំភ្លេចចោលដែរទេ ។

ប៉ុន្មានឆ្នាំក្រោយមកខ្ញុំអាចសម្លឹងមើលទៅក្មេងប្រុសរូបនោះដោយចិត្តទន់ភ្លន់ និងក្ដីស្រឡាញ់ ។ ខ្ញុំបានដឹងហើយឥឡូវនេះ ថាខ្ញុំមិនបានត្រូវគេបំភ្លេចចោលឡើយ ។

ហើយខ្ញុំដឹងពីអ្វីមួយផ្សេងទៀត ។ ក្នុងនាមជាសាវកនៃលោកថៅហ្វាយ គឺព្រះយេស៊ូវគ្រីស្ទ ខ្ញុំសូមប្រកាសដោយភាពប្រាកដ និងការជឿជាក់អស់ពីដួងចិត្តខ្ញុំ --- ដូចជាអ្នកដែរ ! អ្នកមិនត្រូវបានបំភ្លេចឡើយ ។

មិនថាជីវិតអ្នកអាប់អួរយ៉ាងណាទេ មិនថាអ្នកមានអារម្មណ៍ថាមិនសំខាន់យ៉ាងណានោះទេ មិនថាឡើយអ្នកមានស្រមោលអន្ទោលតាមប្រាណយ៉ាងណានោះទេ ព្រះវរបិតាសួគ៌អ្នកមិនដែលភ្លេចអ្នកឡើយ ។ ផ្ទុយទៅវិញ ទ្រង់ស្រឡាញ់អ្នកដោយក្ដីស្រឡាញ់ដ៏អស់កល្ប ។

សូមគិតថា ៖ អ្នកត្រូវបានស្គាល់ ហើយចងចាំដោយអង្គដែលមានឥទ្ធិពល មានអំណាច និងសិរីរុងរឿងបំផុតនៅក្នុងសាកលលោក ! អ្នកត្រូវបានស្រឡាញ់ដោយស្ដេចនៃទីលំហដ៏គ្មានទីបញ្ចប់ និងដ៏និរន្តរ៍ !

ទ្រង់ដែលបានបង្កើត និងស្គាល់តារាទាំងឡាយ ស្គាល់អ្នក និងឈ្មោះអ្នក --- អ្នកគឺជាបុត្រីនៃនគរទ្រង់ ។ ទំនុកដំកើងចែងថា ៖ « កាលណាទូលបង្គំគិតពិចារណាមើលផ្ទៃមេឃ ជាការដែលព្រះហស្តបានធ្វើ គឺទាំងខែ និងផ្កាយ ដែលទ្រង់បានប្រតិស្ឋានទុក នោះតើមនុស្សជាអ្វី ដែលទ្រង់នឹករឭកដល់គេ ? ... ត្បិតទ្រង់បានធ្វើឲ្យគេទាបជាងពួកទេវតាតែបន្តិចទេ ក៏បានបំពាក់សិរីល្អ និងកេរ្ដិ៍ឈ្មោះឲ្យទុកជាមកុដ » [5] ព្រះស្រឡាញ់អ្នក ដោយសារអ្នកជាកូនរបស់ទ្រង់ ។ ទ្រង់ស្រឡាញ់អ្នកទោះជាពេលខ្លះអ្នកមានអារម្មណ៍ឯកោ ឬក៏ធ្វើខុសក្តី ។

ក្តីស្រឡាញ់នៃព្រះ និងព្រះចេស្តានៃដំណឹងល្អដែលបានស្តារឡើងវិញ គឺជាការប្រោះលោស និងការសង្រ្គោះ ។ បើគ្រាន់តែអ្នកអនុញ្ញាតឲ្យក្តីស្រឡាញ់ដ៏ទេវភាពនៃទ្រង់ចូលក្នុងជីវិតអ្នក នោះវាអាចព្យាបាលរាល់របួស រាល់ការឈឺចាប់ និងរំសាយនូវក្តីសោកសៅ ។

បងប្អូនស្រីនៃសមាគមសង្រ្គោះជាទីស្រឡាញ់របស់ខ្ញុំ អ្នកនៅជិតនឹងស្ថានសួគ៌ជាងអ្នកស្មានទៅទៀត ។ អ្នកត្រូវបានបម្រុងទុកលើសពីអ្នកអាចស្រមើស្រមៃទៅទៀត ។ សូមបន្តបង្កើនក្តីជំនឿ និងក្តីសុចរិតផ្ទាល់ខ្លួន ។ សូមទទួលដំណឹងល្អដែលបានស្តារឡើងវិញ នៃព្រះយេស៊ូវគ្រីស្ទ ជាផ្លូវនៃជីវិតអ្នក ។ រីករាយនឹងអំណោយទាននៃសកម្មភាពក្នុងសាសនាចក្រដ៏មហិមានេះ។ សូមសន្សំទុកអំណោយទាននៃការបម្រើក្នុងអង្គការនៃសមាគមសង្រ្គោះដ៏មានពរនេះ ។ សូមបន្តពង្រឹងគេហដ្ឋាន និងក្រុមគ្រួសារ ។ សូមបន្តស្វែងរក ហើយជួយដល់អ្នកដទៃដែលត្រូវការជំនួយពីអ្នក និងព្រះអម្ចាស់ ។

បងប្អូនស្រីទាំងឡាយ គឺមានអ្វីមួយដែលបំផុសគំនិត និងវិសេសបំផុតអំពីផ្កាកុំភ្លេចខ្ញុំដ៏តូចនេះ ។ ខ្ញុំសង្ឃឹមថាវានឹងក្លាយជានិមិត្តរូបមួយនៃរឿងតូចៗដែលធ្វើឲ្យជីវិតអ្នកមានក្តីរីករាយ និងភាពផ្អែមល្ហែម ។ សូមកុំភ្លេចថា អ្នកត្រូវមានចិត្តអំណត់ និងក្តីមេត្តាចំពោះខ្លួនឯង ថាការពលិកម្មខ្លះគឺប្រសើរជាងការពលិកម្មផ្សេងទៀត ថាអ្នកពុំចាំបាច់រង់ចាំសំបុត្រមាសដើម្បីមានក្តីរីករាយនោះទេ ។ សូមកុំភ្លេចថា « ហេតុផល » នៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនឹងបំផុស ហើយលើកដំកើងអ្នក។ ហើយកុំភ្លេចថាព្រះវរបិតាសួគ៌ទ្រង់ជ្រាប ទ្រង់ស្រឡាញ់ និងលើកស្ទួយអ្នក ។

សូមអរគុណចំពោះអ្វីដែលអ្នកមាន ។ សូមអរគុណចំពោះទង្វើនៃក្តីស្រឡាញ់ និងការបម្រើរាប់មិនអស់ដែលអ្នកបានផ្តល់ដល់មនុស្សជាច្រើន។ សូមអរគុណចំពោះអ្វីៗដែលអ្នកនឹងធ្វើដើម្បីនាំមកនូវក្តីអំណរនៃដំណឹងល្អដល់ក្រុមគ្រួសារ សាសនាចក្រ សហគមន៍របស់អ្នក និងដល់ប្រទេសជាតិនានាក្នុងពិភពលោកនេះ ។

យើងស្រឡាញ់អ្នក ។ វាជាការអធិស្ឋាន និងជាពរជ័យរបស់ខ្ញុំថា អ្នកនឹងមិនភ្លេចថាអ្នកគឺជាបុត្រីដ៏មានតម្លៃក្នុងនគរព្រះឡើយ ក្នុងព្រះនាមដ៏ពិសិដ្ឋនៃព្រះអង្គសង្រ្គោះជាទីស្រឡាញ់របស់យើង គឺព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល អេធើរ 12:27 ។
2. សូមមើល នីហ្វៃទី3 12:48 ។
3. Roald Dahl, *Charlie and the Chocolate Factory* (ឆ្នាំ 1964 ) ទំព័រ 48 ។
4. មាត្រានៃសេចក្តីជំនឿ 1:13 ។
5. ទំនុកដំកើង 8:3—5 ។